ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១០

គណៈរដ្ឋមន្ត្រីនឹងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

# សេចក្តីជូនដំណឹង

ព្រះរាជបណ្ណាល័យសូមជូនដំណឹងដល់អស់លោក-អ្នកជាទស្សនា-វដ្ដីកម្ពុជសុរិយាទាំងឡាយៈ

ក្នុងសម័យឥឡូវនេះ អស់លោក-អ្នកគង់បានជ្រាបច្បាស់ហើយថា ទំនិញសព្វសារពើទាំងពួង សឹងឡើងថ្លៃជាអនេកខុសពីឆ្នាំមុនៗ មកច្រើនណាស់ ។ ឯក្រដាសសម្រាប់បោះពុម្ពសៀវភៅ នឹងគ្រឿងប្រដាប់រោងពុម្ពក៏ឡើងថ្លៃច្រើនណាស់ដែរ ថែមទាំងរកទិញបានដោយកម្រផង ហេតុនេះព្រះរាជបណ្ណាល័យនឹងចេញផ្សាយទស្សនាវដ្ដីកម្ពុជសុរិយា ក្នុងកំណត់ ១ ខែពីរដងនោះឃើញថាខាតទុនជាច្រើន ដោយចង់ខាតទៅលើក្របសៀវភៅ បញ្ចូលរឿង នឹងរូបជាដើម ទើបសុំជូនដំណឹងថា ចាប់តាំងពីខែយុកាំងឆ្នាំ ១៩៤២ នេះជាដើមទៅ នឹងកែប្រែរបៀបចេញផ្សាយ ក្នុងកំណត់ ១ខែ ១ ដងវិញ ប៉ុន្តែចំនួនទំព័រនឹងសេចក្ដីផ្ទៃរឿង ប្រហែលក្នុង ១ ខែពីរក្បាលដដែល គឺថាយករឿងក្នុងពីរក្បាលមករួមគ្នាជាមួយក្បាលវិញ ឯលេខរៀងនឹងដាក់តាមលំដាប់លំដោយពីលេខមុនរៀងមកដរាបដល់ចប់ឆ្នាំនេះ ។

ដូច្នេះ សូមចិត្តអស់លោក-អ្នកជាទស្សនាវដ្ដីកម្ពុជសុរិយា កុំបីត្អូញត្អែរ ឬបន្ទោសថាអ្វីឡើយ ការចេញផ្សាយក្នុងកំណត់ ១ ខែ ១ ក្បាល ពិតមែនតែយឺតយូរបន្តិច ប៉ុន្តែវេលាបានមើលម្ដងៗ នាំឲ្យបានមើលសេចក្ដីវែងៗ ច្រើនៗ ជាប់ទាក់ទងគ្នាល្អស្ដាប់ជាងមើលសេចក្ដីខ្លីៗ ចាប់អស់ មិនឆ្ងាយបានចប់រឿងនិមួយៗនោះ ។

# បញ្ជីរឿង


ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌទី ៤ ព្រះធាឡាត់ឃោសនាគ ហ. ចៀវ អាចារ្យបង្រៀន សាលាបាលីជាន់ខ្ពស់សំដែង . . . . . . . . . . . . . . . . ៣

២ — លោកខេយ្យ ពាក្យកាព្យ របស់អ្នកឧកញ៉ាវង្សាសារពេជ្ញ (នង) (តមក) . . ១៣

៣ — អភិធម្មភាសិត ភាគទី ១ របស់លោកគ្រូអាចារ្យ អ៊ុក-ជា ក្រុមជំនុំព្រះត្រៃបិដក (តមកនិងចប់) . . . . . . . . . . . . . . . . . . . . . ១៦

៤ — ពង្សាវតាររោម ស្រង់យកពីគោលបារិកផ្សេងៗក្នុងពង្សាវតារលោក (តមក) ២៥

៥ — ភូមិសាស្ត្រសង្ខេបនៃនានាប្រទេស: អំពីប្រទេសអារ៉ុប . . . . . . . . ២៩


## រូបក្រៅរឿង


រូបព្រះពោធិសត្វអវលោកិតេស្វរៈ បែបរចនាប្រាសាទបាយ័ន (ព. ស. ១៧៤៣) ១

# TABLE DES MATIÈRES


Pages

1. Vidyudesanā (Prédication faite à la Radio Phnôm-Penh), par le Vénérable Achar H. Chieu, Professeur à l'École supérieure de Pāli ........ 3

2. Lokaneyya, poème par feu l'Oknha Vongsā Sarpejñā (Nong) (suite) ........ 13

3. Abhinavabhāsita, pāli et traduction par le Vénérable Achar Ouk-Chéa, membre de la Commission du Tripitaka (suite et fin) ........ 16

4. Histoire de Rome. Extraits de divers documents de l'histoire universelle (suite) ........ 25

5° Géographie sommaire de divers pays: l'Arabie ........ 29


## HORS-TEXTE


Portrait du Bodhisattva Avalokiteçvara — Style de Bayon (1743 E. B.) ........ 1



រូបព្រះពោធិសត្វអវលោកិតេស្វរៈ បែបរចនាប្រាសាទបាយ័ន (ព. ស. ១៧៤៣)

## វិទ្យុធម្មទេសនាកណ្ឌទី ៤

# ព្រះបាឡាត់ឃោសតាគ អាចារ្យសាលាបាលីជាន់ខ្ពស់ សំដែង

ថ្ងៃអង្គារ ៨ កើតខែចេត្រឆ្នាំម្សាញ់ត្រីស័ក ព. ស. ២៤៨៥ (២៤-៣-៤២)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការព្រះអរហំសម្មាសម្ពុទ្ធភគវន្តមុនីព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយសេចក្តីគោរព ។

លំដាប់នេះនឹងសំដែងអំពីកំណើតនៃសេចក្តីសុខជាសង្ខេបតាមកាលវេលា ដូចតទៅនេះ ។

សុខោ ពុទ្ធានមុប្បាទោ ការបានត្រាស់ដឹងឡើងនៃព្រះពុទ្ធគ្រប់ព្រះអង្គជាហេតុនាំឲ្យកើតសេចក្តីសុខ (ជាច្រើនប្រការដល់សព្វសត្វក្នុងត្រៃលោក) ។

អធិប្បាយថា ក្នុងកាលណាមួយៗ, ដែលមានព្រះអរហន្តសម្មាសម្ពុទ្ធបានត្រាស់ដឹងឡើង, កាលនោះសត្វមានចំនួនច្រើនឥតគណនារាប់មិនអស់ តែងបានជួបប្រទះនឹងប្រយោជន៍ សេចក្តីសុខស្ងប់ដ៏ត្រៃលែង ។ ព្រោះព្រះអង្គឧប្បត្តិកើតឡើងទ្រង់ប្រកបដោយសិរីសម្បត្តិដ៏ខ្ពង់ខ្ពស់គួរស្ងើច ជាទីបូជារបស់ពួកជនជាមនុស្ស ហើយបរិបូរដោយចំណេះវិជ្ជាគ្រប់យ៉ាង ព្រមទាំងមានព្រះទ័យពេញព្រៀបដោយសេចក្តីករុណា អាណិត

អាសូរទៅគេពួកសត្វទៅក្នុងត្រៃភពឥតរើសមុខ ។ ព្រះពុទ្ធគោតមាបរមគ្រូ ដែលទ្រង់បានចួបប្រទះនឹងសេចក្ដីសុខក្សេមក្សាន្តខ្ពស់ផុតចំណោមមនុស្ស ដោយគោត្រត្រកូល ពលសម្បត្តិជាដើម ក៏ព្រោះតែកម្មបុណ្យ សេចក្ដីល្អដែលទ្រង់បានកសាងសន្សំទុកជាលំដាប់ជាតិតៗមកដោយពិត ។

មហាការុណិកោ នាថោ ព្រះលោកនាថប្រកបដោយមហាករុណាគុណ ទោះព្រះអង្គបានសេចក្ដីសុខស្រួលដូចម្ដេច ក៏មិនទម្រន់ឲ្យលក់ជក់ជាប់ព្រះទ័យឲ្យទាល់តែលង់គាំងគំនិតដល់ភ្លេចនឹកមិនឃើញការសុខទុក្ខរបស់ពួកសត្វដែលលិចលង់ក្នុងលោកសន្និវាសនេះទេ, ព្រះអង្គមិនព្រមសុខព្រះទ័យទទួលសោយសេចក្ដីសុខដ៏ច្រើនជាផលសំណាងដែលបានមកតាំងនៅស៊ប់ក្នុងកណ្ដាប់ព្រះហស្តរបស់ព្រះអង្គ តែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់ស៊ូលះបង់ប្រយោជន៍ទាំងនោះចោលស្រឡះមិននឹកនា ខំប្រឹងបំពេញព្យាយាមទាល់តែបានសម្រេចប្រាជ្ញាពោធិញ្ញាណលើគេឧបល័ក្ខ ព្រះអង្គបានទីជាសត្ថានាយកៈ អ្នកដឹកនាំស្រោចស្រង់សត្វទាំងឡាយទៅក្នុងលោកឲ្យផុតពីសេចក្ដីទុក្ខលំបាកមាន កើត, ចាស់, ឈឺ, ស្លាប់ជាដើម (ដូចជាសំពៅធំធេង) ។

ចាប់ដើមតាំងពីត្រឹមថ្ងៃដែលទ្រង់បានត្រាស់ដឹងមកទល់នឹងថ្ងៃដែលទ្រង់យាងត្រឡប់ពីដើមកែសខាងត្បូងដើមពោធិព្រឹក្ស មកគង់នៅក្រោមម្លប់ដើមជ្រៃ ជាខាងកើតដើមពោធិព្រឹក្សវិញ នៅក្នុងរវាងពី ៤១ ទៅ

ទល់ទីង ៤៦ ថ្ងៃ ៗ តពីនោះមក ព្រះអរហំសម្ពុទ្ធ ស្ដេចយាងប្រកាសសាសនា ប្រទានទុកទពាក្យប្រៀនប្រដៅណែនាំពួកសត្វមានមនុស្សនិងទេវតាជាដើម, ខំព្រឹងព្យាយាមសំដែងធម៌បំភ្លឺពន្យល់ប្រាប់គុណ, ទោស, ខុស, ត្រូវ ឲ្យសត្វយល់ឃើញពិតៗ ឥតរួញរានិងសេចក្ដីនឿយព្រួយព្រះកាយពលក្នុងការប្រកាសប្រាប់ប្រយោជន៍ដល់សត្វទាំងនោះឡើយ ៗ ព្រះអង្គទ្រង់ព្រឹងបំពេញពុទ្ធកិច្ចគ្រប់គ្រាន់មិនមានចន្លោះ សមស័ក្ដិព្រះអង្គជាសត្ថានាយក អ្នកដឹកនាំស្រោចស្រង់ជាទីពឹងពំនាក់អាស្រ័យនៃសត្វក្នុងត្រៃលោកមែនៗ ទាំងមានព្រះឥរិយាបថស្រគត់ស្រគំសមរម្យ, មានព្រះអធ្យាស្រ័យក៏ទន់ភ្លន់ស្លោះស្មើ ស្លូតត្រង់ទៅរកសត្វទូទៅ, គួរជាប់ចិត្តលួមឲ្យមនុស្សទេវតានិងសត្វគ្រប់ថ្នាក់ទាំងទាប-ខ្ពស់មានសេចក្ដីសង្ឃឹមកក់ក្ដៅចូលទៅជ្រកកោនក្រោមម្លប់ពោធិសម្ភារបានសម្រេចសន្តិសុខតាមប្រាថ្នា; ព្រះអង្គមានទំនងគួរឲ្យសត្វក្នុងសាកលលោកគោរពក្រាបសំពះយកគម្រាប់តាមដោយសេចក្ដីពេញចិត្តមិនបាច់បង្ខំ ៗ

ព្រះពុទ្ធគុណដែលរៀបរាប់ដោយសង្ខេបមកខាងលើនេះ បើពោលបំប្រួញឲ្យខ្លីងាយចំណាំជាងនោះមកទៀតថា: ព្រះអរហំសម្មាសម្ពុទ្ធជាបរមគ្រូ ទ្រង់មានព្រះទ័យស្អាត មិនប្រឡាក់ដោយបាបសេចក្ដីអាក្រក់ណាមួយ ហៅថា វិសុទ្ធិគុណ, ទ្រង់ខំព្រឹងបំពេញប្រយោជន៍ឲ្យសត្វបានទទួលសេចក្ដីសុខតាមគតិលោកគតិធម៌ស្មើៗគ្នា សមគួរដល់ភ័ព្វសំណាង

សត្វ មិនលាក់បិទប្រយោជន៍ទុកសម្ងំសោយសេចក្ដីសុខស្រួលតែមួយព្រះអង្គឡើយ ហៅថា ករុណាគុណ, ទ្រង់មានឧបាយដ៏ប្រពៃក្នុងការទូន្មានសត្វ ធ្វើសេចក្ដីជ្រៅឲ្យរាក់ កំបាំងឲ្យងាយយល់ងាយគិតជាដើម ហៅថា បញ្ញាគុណ ។ ដោយហេតុនេះទើបប្រាកដថាព្រះពុទ្ធគ្រប់ព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ជាហេតុនាំឲ្យបានសេចក្ដីសុខ (ដល់ពួកសត្វក្នុងត្រៃភព) ។

សេចក្ដីដែលសំដែងមកនេះ ជាគុណដែលមានក្នុងព្រះអង្គ ។

ស្វាក្ខាតោ ភគវតា ធម្មោ ធម៌ដែលព្រះភគវន្តសម្ពុទ្ធសំដែងដោយប្រពៃ មានគុណអាចស្រោចស្រង់ពួកសត្វលោកដែលពេញចិត្តកាន់តាមឲ្យផុតអំពីទុក្ខទោស បានសេចក្ដីសុខស្រួលឃើញជាក់ច្បាស់ចំពោះមុខភ្លាមៗតាមថ្នាក់តាមជាន់ឥតបង្អង់ចាំកាលវេលា ។ ធម្មោ សុចិណ្ណោ សុខមាវហាតិ ធម៌ដែលសត្វបានរក្សាទុកត្រឹមត្រូវនឹងផ្ដល់សេចក្ដីសុខមកឲ្យវិញពុំខាន ។

អធិប្បាយថា: អំពើល្អហៅថាធម៌, អ្នកប្រព្រឹត្តត្រូវតាមធម៌ ឈ្មោះថាបានរក្សាធម៌ទុកដោយប្រពៃ នឹងត្រូវបានផលជាសុខ; អំពើអាក្រក់ហៅថាអធម៌ គឺមិនមែនធម៌; អ្នកមិនកាន់តាមធម៌ ឈ្មោះថាមិនរក្សាធម៌បែរទៅប្រព្រឹត្តអាក្រក់ ដែលមិនមែនជាធម៌ នឹងត្រូវបានផលជាទុក្ខ ។

រួមព្រះធម៌ទាំង ៨៤០០០ ធម្មក្ខន្ធដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង ហៅថា ពុទ្ធសាសនា ។

អស់លោក-អ្នកជាសាធុជនទាំងឡាយ ដែលពេញចិត្តគាប់អធ្យាស្រ័យ ចង់បានប្រយោជន៍ សេចក្តីសុខចំរើនត្រឹមតែក្នុងលោកនេះក្តី ឬក៏ចង់ប្រាថ្នាដល់ទៅលោកខាងនាយទៀតផងក្តី គួរតែប្រឹងឆ្វៀតបង្អោនចិត្តចូលមកកាន់ព្រះពុទ្ធសាសនាខ្ពះកុំខាន ព្រោះព្រះពុទ្ធសាសនានេះអ្នកប្រាជ្ញជាន់ខ្ពស់ក្នុងលោកឃើញពិតថាជាសាសនាមានអានុភាព អាចធ្វើលោកឲ្យស្ងប់, ទាំងញុំាងមនុស្សសត្វដែលទន់ទាបថោកថយឲ្យខ្ពង់ខ្ពស់ថ្លៃថ្នូរ, បើថ្លៃថ្នូរស្រាប់ ឲ្យរឹងរឹតតែវិសេសក្រៃលែងឡើងទៀត ។ សេចក្តីដែលពណ៌នាមកនេះ ត្រង់តាមគោលដើមនៃពុទ្ធបំណងពិត; ព្រោះព្រះអង្គដែលខំប្រឹងព្យាយាមសំដែងច្បាប់ប្រាប់ពន្យល់ មិនគិតនឿយហត់ទាំងម៉្លេះ ដោយទ្រង់មានព្រះទ័យករុណាចង់ស្រោយដោះពួកសត្វដែលជាប់ចំណងនៃសេចក្តីទុក្ខលំបាកមានជាតិ, ជរា, ព្យាធិ, មរណជាដើមឲ្យរួចចាកទុក្ខបានសេចក្តីសុខស្កប់ស្កល់ប៉ុណ្ណោះ ។ សូមអស់លោក-អ្នកស្តាប់ៗហើយកំណត់ទុកក្នុងចិត្តចុះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា ពួកមនុស្សសត្វកើតមកពេញទាំងសាកលលោក សុទ្ធសឹងតែប្រាថ្នាសេចក្តីសុខខ្ពង់ខ្ពស់ថ្លៃថ្លាគ្រប់ៗរូប, ដែលថែរជាបានសេចក្តីអាប់ឱនទន់ទាប មិនសមដូចបំណងស្មើគ្នា

ទៅវិញនោះ បណ្តាលមកពីហេតុច្រើនយ៉ាងណាស់, ខ្លះកើតឡើងដោយសេចក្តីទន់ទាបក្រីក្រល្ងង់ខ្លៅស្រាប់មកពីកំណើតក៏មាន ព្រោះផលបុញ្ញតិច, ខ្លះកើតមកបានចួបប្រទះនឹងសេចក្តីចំរើនសម្បូណ៌សម្បត្តិគ្រប់គ្រាន់ស្រាប់ពីកំណើត តែធ្វេសភ្លេចគិត ទម្រើសខ្លួនបណ្តោយចិត្តឲ្យទៅប្រព្រឹត្តអាក្រក់ទាស់ទំនង ពានទៅលើអំពើមិនមែនជាធម៌ បានសេចក្តីថ្លស់ធ្លោយធ្លាក់ខ្លួនជាអ្នកទន់ទាបអាប់ឱនខ្លួនទៅវិញក៏មាន, ខ្លះទប់ខ្លួនឲ្យនៅត្រឹមតែស្មើៗមិនទាបមិនខ្ពស់ក៏មាន តាមសមគួរដល់អំពើដែលសត្វបានធ្វើរៀងខ្លួន; ដូចពុទ្ធភាសិតថា សត្តេ កម្មំ វិភជ្ជតិ កម្មគឺអំពើដែលសត្វធ្វើទុកមកពីជាតិមុន ឬជាតិនេះ, ជាមេចំណែកចែកឲ្យសត្វបានសុខបានទុក្ខផ្សេងៗគ្នា មិនមែនអ្វីផ្សេងក្រៅពីអំពើរបស់ខ្លួននោះចែកឲ្យឡើយ ។

ឯអំពើអាក្រក់មិនត្រូវតាមផ្លូវធម៌ នាំមនុស្សឲ្យវិនាសបានសេចក្តីទុក្ខលំបាកទាំងលោកនេះនឹងលោកខាងមុខនោះដូច្នេះ ។

អបាយមុខ ហេតុនាំឲ្យវិនាសចាកសេចក្តីចំរើន ៤ យ៉ាងគឺ:

១ - ឥត្ថីធុត្តៈ អ្នកជោកចិត្តជក់នឹងមាតុគ្រាម មិនមានចិត្តសន្តោសត្រឹមតែភរិយា - ស្វាមីរបស់ផងខ្លួន ។

២ - សុរាធុត្តៈ អ្នកសេពគ្រឿងស្រវឹង

៣ - អក្ខធុត្តៈ អ្នកលេងល្បែងភ្នាល់

៤ – បាបមិត្តៈ អ្នកគប់រកមនុស្សអន្ធពាលអាក្រក់ជាមិត្ត ។

ហេតុទាំង ៤ នេះសុទ្ធសឹងតែជាអំពើអាក្រក់អាចនាំឲ្យប្រទេសជាតិ ភោគសម្ប័ទចំណេះវិជ្ជាចរិយាស្រកស្រុតចុះថោកទាប, នាំឲ្យវិនាសថ្វស់ ក្លាយខូចបង់ប្រយោជន៍សេចក្តីសុខចំរើនរបស់មនុស្សក្នុងសាកលលោក ជាក់ស្តែងភ្លាមៗ; មិនបាច់ពោលថ្វីដល់ទៅលោកខាងមុខនោះឡើយ ។ មែនពិត, អំពើទាំងនេះ, បើសត្វខំប្រឹងប្រព្រឹត្តជាប់មិនលែង, លោក ពោលថា ទុកដូចជាយកគប់ភ្លើងយ៉ាងធំមកដុតពេលកំឡោចបំផ្លាញភោគ-សម្ប័ទ ចំណេះវិជ្ជា ចរិយា មារយាទ ជាតិកំណើតនិងសន្តិសុខដ៏រុងរឿង របស់ខ្លួនឲ្យខ្លោចក្រិនខូចលែងលូតលាស់ដុះចំរើនឡើងទៀតរួច ចេះតែ រេចរិលចុះទៅជានិច្ច ឈ្មោះថាជាមនុស្សជួញទុក្ខ ។

សាធុជនជាសប្បុរសគួរកុំប្រព្រឹត្តអំពើទាំងនេះឲ្យសោះ, កាលបើ សាធុជនបានវៀរចាកអំពើទាំងនេះរួចស្រឡះហើយ ឈ្មោះថាបានប្រ-ព្រឹត្តធម៌រក្សាធម៌ទុកដោយប្រពៃ នឹងបានផលជាសុខច្រើនប្រការ; បើ ពោលដោយសង្ខេបវិញគឺៈ ១ – សុខព្រោះមានចិត្តស្រុះស្រួលស្មោះស្មើ ទៅរកភរិយា-ស្វាមី ដោយមិនជាប់ចិត្តនឹងស្ត្រីបុរសឯទៀត; ២ – សុខ ព្រោះមានសំដីកបសាជាប្រក្រតី, មិននិយាយឡេះឡោះកកៃកករករឿង ឈ្លោះមិនខូចបង់ប្រាក់កាសដោយហេតុមិនសេពសុក; ៣ – សុខព្រោះ បានធ្វើការងារចំរើន រៀនវិជ្ជាចេះចាំមិនភ័យនឹងអ្នករាជការចាប់ចងឃុំឃាំង

លក់ថ្លៃដោយហេតុមិនលេងល្បែងភ្នាល់; ៤ – សុខព្រោះមានចិត្តស្លូតត្រង់ មិនចេះធ្វើអំពើអាក្រក់ដោយហេតុមិនសេពគប់រកជនពាល ។

៦ ការគប់រកជនពាលអាក្រក់ នាំឲ្យចេះចំណេះអាក្រក់ ព្រោះមនុស្សពាលមិនដែលនាំឲ្យប្រព្រឹត្តល្អទេ មិនស្គាល់ហេតុនាំឲ្យបានសុខ ស្តាប់ពាក្យគ្រូមិនសូវបាន, បើអ្នកដែលទៅសេពគប់ផងនោះ មិនចេះលេងស្រី នាំឲ្យចេះលេង, មិនចេះសេពសុរា នាំឲ្យចេះ, មិនចេះលេងល្បែងភ្នាល់ នាំឲ្យចេះលេង, រហូតដល់ទៅនាំឲ្យចេះដើរលេងយប់, បោកប្រាស់បំបាត់ប្រព័ន្ធគេ ធ្លាក់ដល់ចេះលួចប្លន់កាប់សម្លាប់គេក៏សឹងមាន; ត្រូវនឹងពុទ្ធភាសិតថា "អសេវនា ច ពាលានំ ការមិនគប់រកពួកជនពាល ចាត់ជាមង្គលដ៏ប្រសើរ" ។ អ្នកដែលបានរៀរចាកអំពើអាក្រក់ដូចពោលមកហើយនេះ ទុកដូចជាអ្នកបានបណ្តុះប្រ-យោជន៍ដ៏ធំទូលាយចំពោះខ្លួនផង ទុកសម្រាប់ប្រទេសជាតិឲ្យបានចំរើនទៅខាងអនាគតផង ។ សេចក្តីសុខទុក្ខទាំងនេះកើតមកអំពីកម្មផ្ទាល់ខ្លួនពិត ៗ ។ ការលះបង់អបាយមុខមានប្រយោជន៍ធំទូលាយក្រៃពេក ដែលពោលមកនេះជាសេចក្តីសង្ខេប ។ អ្នកប្រាជ្ញជាន់ខ្ពស់ដែលមានឈ្មោះចុះទុកជាប់ក្នុងប្រវត្តិសាស្ត្រក្នុងលោកតរៀងមកដរាបដល់សព្វថ្ងៃនេះក្តី ដែលកំពុងមានសព្វថ្ងៃនេះក្តី កាលបើលោកគិតប្រកបការណាមួយជា

ប្រយោជន៍ខ្លួនទឹងប្រទេសជាតិជាដើម សុទ្ធតែលោកលះអបាយមុខទាំង ៤ នេះចោលចេញស្រឡះ ទើបធ្វើការនោះបានសម្រេចដូចបំណង ។

មិនត្រឹមតែប៉ុណ្ណោះដែលហៅថាសាសនាបរិសុទ្ធនោះ គឺជាសាសនាអាចជ្រោងលោកឲ្យលឿនទៅកាន់សេចក្តីចំរើន ទប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីថោកទាបមាននរកជាដើម ឲ្យលោកបានសេចក្តីសុខស្ងប់ ទាំងធ្វើឲ្យអ្នកជឿស្តាប់កាន់តាម បានប្រទះប្រយោជន៍សេចក្តីចំរើនដោយភោគ-សម្ប័ទ បញ្ញាសម្ប័ទ កេរ្តិ៍ឈ្មោះយសស័ក្តិតាមសមគួរ មិនមែនសំដែងប្រាប់ឲ្យមនុស្សសត្វដេកទម្រន់ចាំសំណាងពីព្រេងនាយតែម្យ៉ាងទេ ដូចពុទ្ធភាសិតមានដើមថា សុស្សូសំ លភតេ បញ្ញំ អ្នកមានប្រាជ្ញាចេះបំណេះវិជ្ជាគ្រប់យ៉ាងបានមកពីប្រឹងរៀនស្តាប់ទន្ទេញ មិនធ្វេសប្រ-ហែសក្នុងការរៀនសូត្រ; ឧដ្ឋាតា វិន្ទតេ ធនំ អ្នកមានទ្រព្យធនគ្រប់គ្រាន់ មកពីរវៀសរវៃប្រឹងរកប្រឹងធ្វើមិនខ្ជិល ។ សេចក្តីដែលសំដែងមកប៉ុណ្ណោះតាមលំអានព្រះពុទ្ធសាសនា ជាសាសនាប្រាប់ផ្លូវប្រតិបត្តិយ៉ាងកណ្តាល មិនឲ្យសត្វកាន់ឆាកធ្លាក់ទៅលើផ្លូវប្រតិបត្តិច្រើន ដែលហៅថា អន្តាបដិបទា សេចក្តីប្រតិបត្តិដ៏លាមក ឬអមខាងនោះឡើយ មានទំនងឲ្យពួកពុទ្ធបរិស័ទនាំគ្នាកាន់តាមសេចក្តីពេញចិត្តឥតបង្ខិតបង្ខំ ។ ព្រោះហេតុនោះ ទើបអធិប្បាយថាជាសាសនាស្អាងលោកឲ្យរុងរឿង ទប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីទាប ។

សូមអស់លោក-អ្នកជាសប្បុរសទាំងឡាយ កំណត់ចាំទុក ហើយប្រតិបត្តិយកប្រយោជន៍ តាមគួរដល់អធ្យាស្រ័យចុះ ៗ សំដែងមកដោយសង្ខេបតាមគួរដល់វេលា សន្មតជាចប់ត្រឹមប៉ុណ្ណេះ ឯវំ ៗ

សូមឲ្យជោគជ័យសិរីសុខគ្រប់ប្រការមានដល់អស់លោកអ្នកស្តាប់ទាំងឡាយ អស់កាលជានិច្ចតរៀងទៅ កុំបីឃ្លាតឡើយ! ៗ

ព្រះបាឡាត់ឃោសនាគ អាចារ្យសាលាបាលីជាន់ខ្ពស់ ។

## លោកនេយ្យ

### ពាក្យកាព្យ (តមក).

បទពំនោលទូវសាសន៍ ថ្លែងពីទំនង ដំណើរព្រះពន្សពោធិ ។ ទូវកដបណ្ឌិតទាំងបី ដួបចូលកសិ ប្រាំដណ្តប់ឆ្នាំហើយណា ។ ឯអគ្គ ព្រះមហាក្សត្រា ស្តេចពិចារណា គិតថាឥឡូវធនញ្ជ័យ ។ ប្រយ័ត្នខ្លួនក់ ពេកក្រៃ ពុំឲ្យយល់នៃ កំហុសក់ដល់តិចឡើយ ។ បើក់លែងគាល់អញ ហើយ ឥតអ្នកណាឡើយ នឹងអាចយកទោសក់បាន ។ គួរអញរកកល គិតផ្សាន ស្រដីឲ្យបាន ញឹកៗទឹងជាប្រក្រតី ។ មានកាលមួយថ្ងៃពោធិ នឹងអ្នកទាំងបី ឡើងទៅគាល់មហាក្សត្រា ។ ទើបស្តេចបន្ទូលទៅថា ម្នាល អស់អាចារ្យ នាចិត្តព្រះស្តែងសព្វថ្ងៃ ។ ចង់ប្រយោជន៍ឲ្យអញក្រៃ ឬ ចង់ឲ្យនៃ អាត្មាឯងចូរចចា ។ អាចារ្យទាំងបីអគ្គា ទូលព្រមឡើងថា បពិត្រព្រះមហាក្សត្រក្សាន្ត ។ យើងខ្ញុំទាំងបីនេះមាន ចិត្តចង់ឲ្យបាន ប្រយោជន៍អម្ចាស់ពេកក្រៃ ។ ឯប្រយោជន៍ខ្លួនឯងនៃ ពុំគិតសង្ស័យ ពុំមានដល់តិចឡើយណា ។ ព្រះពោធិសត្វសោភា ស្តាប់ពាក្យនោះណា អ្នកសើចហើយអ្នកស្ងៀមនៅ ។ ទើបស្តេចបើកបន្ទូលទៅ ត្រាស់ថាហៃ ទៅ ធនញ្ជ័យចិត្តបាតើម្តេច ។ ពង្សពុទ្ធង្កូលសរពេជ្ញ ទូលថាសម្តេច មហារាជឥស្សូរសិរសា ។ សព្វថ្ងៃប្រយោជន៍អាត្មា ខ្ញុំសឹងប្រាថ្នា ប្រយោជន៍អម្ចាស់ថ្ងៃក្តី ។ សឹងគិតបំពេញចក្រិ ទាំងបទអ្សីៗ អញខ្ញុំ នឹងទូលឡើយណា ។ ក្សិណនោះឯសុន្ទរ- លៃយទូលកិច្ចការ បពិត្រ

ព្រះបាទក្សត្រថៃ ៗ ឃើញខ្ញុំយល់ចិត្តធនញ្ជ័យ បណ្ឌិតសព្វថ្ងៃ ចង់តែប្រយោជន៍ខ្លួនពិត ៗ ប្រយោជន៍អម្ចាស់ពុំគិត សព្វថ្ងៃជីវិត រស់ដោយព្រះរាជទាន ៗ គាត់ពុំគិតគុណក្សត្រក្សាន្ត សព្វថ្ងៃនេះមាន ចិត្តចង់ចម្រាសក្សត្រា ៗ ស្ដេចស្ដាប់ពាក្យសុន្ទក-វៃលយក្រាបទូលថា ម្ដោះក្ត់សព្វព្រះហឫទ័យ ៗ ទើបស្ដេចបន្ទូលថាហៃ សុន្ទកវៃលយ បទអ្វីទៅថាដូច្នោះ ៗ សុន្ទកវៃលយទូលស្នោះ នាខ្ញុំទូលនោះ ដ្បិតខ្ញុំយល់ទៅធនញ្ជ័យ ៗ ធ្វើធ្វើនអំនួតធំក្រៃ លន់ពន់សព្វថ្ងៃ ខុសទំនងក្នុងនរអ្នកផង ៗ មានកេរ្ដិ៍ប្រាំរយជាមួយ កើតថ្ងៃព្រមផង ឲ្យគាល់ឲ្យហៃប្រក្រតី ៗ បពិត្រអម្ចាស់សិរីសី យល់ហេតុសេចក្ដី ដូច្នោះទើបខ្ញុំទូលថា ៗ ចង់តែប្រយោជន៍អាត្មា ប្រយោជន៍ក្សត្រា ពុំធ្វើដល់តិចឡើយនៃ ៗ ឥដ្ឋា-ម្មណ៍ទូរអភ័យ បណ្ឌិតនោះនៃ ខ្លះថាបពិត្រក្សត្រា ៗ ពាក្យសុន្ទក-វៃលយថា ទូលព្រះរាជា មែនពិតដូច្នោះឯងហោង ៗ ស្ដេចស្ដាប់ហើយស្ដេចត្រាស់ផង ធនញ្ជ័យនេះម្ដង គេថាដូច្នោះប្ដី ៗ កាលនោះព្រះពង្សរោធ៍ ស្ដាប់ហើយនៃ្ទ បង្គំប្រណម្យទូលថា ៗ បពិត្រសម្ដេចរាជាពិតដូចគេថា ទំនងបន្ទោសនរណាឡើយ ៗ ទោសដ្បិតកុសលខ្ញុំហើយបានសាងជាត្រើយ អំពីបុណ្យណានាយណា ៗ នាំមកឲ្យកើតនៅនាត្រកូលនៃមហា- សេដ្ឋីប្រសើរមានទ្រព្យ ៗ ទើបមានបរិពារសឹកប់ ទាំងប្រាំរយស្រាប់ កែងគាល់កែងហែសព្វថ្ងៃ ៗ ហើយមានប្រាជ្ញាពន់វៃ

ដោះទុក្ខក្សត្រថៃ ព្រះអង្គទ្រង់ព្រះមេត្តា ៗ ឲ្យជូនជំនូនភោគ្គា ច្រើនក្រៃ
មហិមា មួយសែនៗសព្វថ្ងៃ ៗ ទើបឲ្យគេខឹងស្អប់ក្រៃ មកទូលក្សត្រ
ថៃ កាច់ឲ្យព្រះអង្គខ្ញាល់ផង ៗ បើកើតដូចគេនោះហោង ជាកូនជកទង
ម្តាយដើរទៅរកប្រុសវិញ ៗ សមបានជាមិត្រសំឡាញ់ ពុំនោះសោត
មិញ កើតជាកូនអ្នកសសន់ ៗ ដើរលេងដេកលេងតំបន់ គេពុំដិនផ្អន់
សមបានជាមិត្រផងគ្នា ៗ ពុំនោះបើទៅកើតជា កូនអ្នកលេងរ៉ា តែងសូម
គេធ្វីសព្វស្រុក ៗ ដូចគេនោះសមបានសុខ ជាមិត្រឥតទុក្ខ គិតគេខឹង
ផងឡើយណា ៗ បពិត្រសម្តេចក្សត្រា សព្វថ្ងៃនេះណា ឈឺផ្អាលព្រះ
បាទបក្រី ៗ ពុំឈឺផ្អាលអម្ចាស់ក្តី ពោះធ្វើស្វាមី- ភក្តីស្វាមីភក្តិនោះ ៗ
នរណាមួយចិត្តចង់ស្មោះ ប្រយោជន៍ថ្វាយឆ្ពោះ មិនចង់ឲ្យប្រយោជន៍ក្តី ៗ
ខ្ញុំដឹងខ្ញុំពុំប្រណី ពុំបាច់បក្រី ស្តេចជ្រាបក្នុងព្រះទ័យា ៗ រាជបណ្ឌិត
ទាំងបីរ៉ា ខឹងហើយទូលថា បពិត្រក្សត្រថៃបញ្ហាស់ច្បង ៗ ធនញ្ជ័យដឹង
មែនពិតហោង ដ្បិតគាត់ប៉ុនប៉ង ដណ្តើមរាជ្យទឹងព្រះអង្គ ៗ ស្តែង
ស្តេចស្តាប់ហើយពុំលង់ បន្ទូលត្រាស់ត្រង់ ថាហៃធនញ្ជ័យបណ្ឌិត ៗ
ព្រះស្តែងប៉ុនប៉ងគំនិត ទឹងក្បត់អញពិត ឬម្តេចចូរចៅចរចា ៗ ព្រះ
ពោធិសត្វទូលថា ខ្ញុំទៅតែរ៉ា ទាំងបីទឹងក្បត់ព្រះអង្គ ៗ កាលត្រាស់
ឲ្យហៅទៅក្នុង ប្រាសាទកំឡុង ព្រះរាជមន្ទីរក្សត្រថៃ ៗ រីឯសុន្ទរ-
ពៃយ យល់រូបអស់ស្រី ព្រះស្នំអម្ចាស់ថ្ងៃថ្វា ៗ (នៅមានត)

# អភិធរភាសិត

## ភាគទី ១

(តមកពីលប់)

ញុំ វត្ថុំ បរិចជ្ជ យោ' ញុំ វត្ថុ សេវតេ
ញុកញុក ឱកោ តស្ស វិឌស្សន្តិ ន សំសយា.

នរអ្នកណា មានចិត្តសាហ៍ ទៅលះបោលបង់
វត្ថុដែលទៀង ហើយទៅត្រេកត្រង់ សេពវត្ថុផ្សេង មិនទៀងវិញណា;
វត្ថុទៀងមិនទៀង ទាំងពីរគង់ឃ្លៀង ឃ្លាតមិនជាប់ពេ
ជននោះនឹងបង់ ខាតខូចអាសា ឥតបានត្រង់ណា កុំសង្ស័យឡើយ.

ចក្ខុមា'ស្ស 'បថា អន្ធោ...

នរអ្នកណា មាននយនេត្រា ល្អិតល្អក់ថ្លា
តែបើមិនចេះ អក្សរសាស្ត្រា អ្នកនោះលោកថា មានភ្នែកៗខ្វាក់;
ធម្មជាតិគាត់តែង បង្កើតភ្នែកឯង ឲ្យមើលជ្រៅពក់
មិនឲ្យទើសទាល់ ឲ្យសល់ជំពាក់ មិនឲ្យធ្វើខ្វាក់ មើលអ្វីមិនបាន.

“បាក-បេរគាថា”

គតិលោកថា:

“អ្នកចេះអក្សរ លោកឲ្យនាមករណ៍ ថាមានភ្នែកទិព្វ...”

## ភាសិតខ្ញុំ[១]ថា:

“អ្នកមិនចេះអក្ខរ លោកឲ្យនាមថា ជាមនុស្សភ្នែកខ្វាក់”

សជាតិ សាសនំ បិយ! អត្តនោ បបរី រក្ខ!
នានាសិប្បំ ពហុំ គណ្ហា! រដ្ឋំ នោ ឧបសោភតិ!
ចូរស្រឡាញ់ជាតិនិងសាសនា! និងផែនពសុធាដីទឹកយើង
ចូរនាំគ្នាខំរៀនសូត្រឡើង! ទើបផែនយើងចម្រើនទាន់សម័យ!

“ដក-ភាសិតខ្ញុំ”

សជាតិ សាសនំ បិយ! បបរី ជីវិតសមំ!
មតំ ជីវំ ន ចិន្តេតិ តេស'ត្ថាយ ជីវំ ជហេ!
ចូរស្រឡាញ់ជាតិនិងសាសនា និងផែនពសុធាស្មើជីវិត
ទោះស្លាប់ទោះរស់មិនត្រូវគិត ត្រូវលះជីវិតជួសតាងវិញ!
សព្វេ បុរិសា ឥត្ថិយោ សព្វវិជ្ជំ ឧគ្គណ្ហេយ្យុំ!
សព្វេវ បណ្ឌិតា ហោន្តុ! រដ្ឋ'ម្ហាកំ វិរោចតិ!
ជាតិមនុស្សប្រុសស្រីគប្បីរៀន ចំណេះរបៀនសព្វវិជ្ជា!
ឲ្យបានចេះដឹងដូចៗគ្នា ទើបបានថ្លៃថ្លាដល់ជាតិស្រុក!

“ដក- បញ្ញាសុមាលី”

---

១ ពាក្យថា: “ភាសិតខ្ញុំ” នេះ មិនមែនជាភាសិតរបស់អ្នកសរសេរសៀវភៅនេះទេ គឺជាឈ្មោះគម្ពីររបស់អ្នកប្រាជ្ញពីបុរាណមក ។

សព្វទព្វេសុ វិជ្ជា វ  ទព្វ’មាហុរនុត្តមំ

អហោរតា  អនគ្ឃតា  អក្ខយតា ច សព្វទា.

វិជ្ជាវិសេសលើសទ្រព្យធន  ចោរមិនអាចប្លន់ឆក់លួចបាន

វិជ្ជាគ្មានថ្លៃទឹងប្រមាណ  ប្រើចេះតែបានគ្រប់វេលា !

“ ពាក - បញ្ញាសុមាលី ”

សព្វា សិប្បវិជ្ជាយេវ  វីរិយេន នោ’ប្បជ្ជន្តិ

សព្វានិ ទព្វជាតានិ  ឯសនាយ នោ វឌ្ឍន្តិ?

សិល្បសាស្ត្រវិជ្ជាទឹងកើតឡើងដោយព្យាយាមយើងកល់ៗគ្នា

ទ្រព្យធនទឹងកើតទឹងវឌ្ឍនាដោយយើងកល់គ្នាប្រឹងរកណា .

“ ពាក - ភាសិតខ្ញុំ ”

ន សយំ វិជ្ជា ឯសនា-  បត្ថេនេន ឧប្បជ្ជន្តិ

ន ទព្វជាតានិ យស្មា’-  ធុស្សហិកាស្សុប្បជ្ជន្តិ.

វិជ្ជាមិនដែលកើតឡើងឯង  ដោយឥតគេស្វែងគេប្រាថ្នា

ទ្រព្យធនមិនកើតដល់អ្នកណា  ដែលគ្មានឧស្សាហ៍ខំប្រឹងរក.

“ ពាក - ភាសិតខ្ញុំ ”

ពាលោ និរត្ថកំ ជីវេ  តស្សេវ មរណំ សេយ្យោ

ជនា ហិ តំ ន ភេចន្តិ  បិហាយន្តិ វ ខាណុកា.

មនុស្សល្ងង់រស់នៅឥតអំពើ ស្លាប់វិញគ្រាន់បើប្រសើរជាង
រស់នៅឲ្យគេឃើញរូបកង ប្រឆេងប្រឆាងទទឹងទាស់.

"ចាក - ភាសិតខ្ញុំ"

មនុស្សជាតិ ជានេយ្យ - សត្ថានេ ច សិប្បវិជ្ជំ
តិរច្ឆានំ ន ការេយ្យ នត្ថិ ចោតំ សារោ សារោ.

កើតមកជាមនុស្សត្រូវតែចេះ វិជ្ជាចំណេះក្នុងសន្តាន
មិនត្រូវធ្វើខ្លួនដូចតិរច្ឆាន គ្មានខ្លឹមក្នុងប្រាណបន្តិចសោះ.

"ចាក - ភាសិតខ្ញុំ"

មតា' ហិ មណ្ឌុកា ជីវេ ឥវ សេវេ សិប្បវិជ្ជំ
យថាកម្មំ ន វសេយ្យ ន អាគមេយ្យ វាសនំ.

កុំស្លាប់ដូចពស់រស់ដូចកង្កែប គួរប្រឹងគប់សេពសិប្បវិជ្ជា
កុំបណ្តោយតាមយថាកម្ម កុំចាំវាសនាលើកបាយបញ្ចុក.

"ចាក - ភាសិតខ្ញុំ"

ន សិយា លោកវឌ្ឍនោ.

កើតមកជាមនុស្ស តោងស្គាល់ត្រូវខុស គុណទោសនានា
ត្រូវរករៀនសូត្រ សិប្បវិជ្ជា ទុកក្នុងអាត្មា ឲ្យបានច្រើនឡើង;
មិនត្រូវកើតមក មិនចេះលៃលក រកការថ្កុំថ្កើង
ធ្វើខ្លួនឲ្យល្ងង់ គេកែមិនឡើង ហើយប្រឹងបើងថាខ្លួនគ្រាន់បើ.

ជាតិមនុស្សបែបនេះ អ្នកប្រាជ្ញដែលបេះ ថាឥតអំពើ
កើតមកជាមនុស្ស មកធ្វើក្អើៗ ស្លាប់វិញគ្រាន់បើ មិនចង្អៀតលោក;
មនុស្សនេះលោកថា ចម្រងបន្ទា ស្អុតស្អាញក្អងលោក
នាំឲ្យចង្អៀត គេឯងគរគោក នាំសោកមមោក អាក្រក់ពេកកួរ.

"ពាក - ធម្មបទ"

អសន្តំ យោ បគ្គណ្ហាតិ អសន្តមុបសេវតិ
តមេវ ឃាសំ កុរុតេ ព្យគ្ឃោ សជីវកោ យថា.

នរអ្នកណា ក្រស្តប្ពុកជា មុខមន្ត្រីផង
បានលើកដំកើង មនុស្សពាលយង់ឃ្នង កប់ប្រសព្វផងទឹងក៏នោះឯង;
នរអ្នកនោះ តែងនឹងបានលុះ ផលកាចជាក់ស្តែង
ដែលពាលក៏សង សំណងនោះឯង ដូចសញ្ជីវៈថ្វែង ព្រោះខ្លាឲ្យរស់.

"ពាក - មង្គលត្ថទីបនី"

អត្តានំ ន ទទេ បោសោ
កើតមកជាមនុស្ស ទោះបីស្រីប្រុស ចាស់ក្មេងក៏ដោយ
គួររក្សាខ្លួនកុំឲ្យថ្វស់ធ្លោយ កុំបីបណ្ដោយឲ្យជាខ្ញុំគេ;
ធម្មតាខ្ញុំគេ លំបាកឥតល្ហែ គ្មានទំនេរទេ
ធ្វើការមួយរួច ត្រូវធាកបែររេ នឹងនៅទំនេ ពុំបានឡើយណា.

"ពាក - សំយុត្តនិកាយ"

យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ.

អ្នកដែលរស់នៅអស់រយវស្សា តែគ្មានប្រាជ្ញាដឹងការពក់ជ្រៅ
ចិត្តតាំងមិនទឹងបេះតែសៅដៅ អ្នកនោះលោកហៅរស់ឥតអំពើ.
អ្នកមានប្រាជ្ញាបេះសព្វអន្ទើ ស្ងឹងស្ងាធំនៅស្ញើគិតពិតារណា
អ្នកនោះរស់នៅថ្ងៃមួយគង់ជា បានឈ្មោះហៅថារស់នៅប្រសើរ.

"ពាក-ធម្មបទ"

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ

អ្នកដែលរស់នៅអស់តាំងរយឆ្នាំ តែខ្ជិលក្រជាំព្យាយាមកយមាយ
ស៊ីដេកៗមិនគិតខ្វល់ខ្វាយ អ្នកនោះលោកម៉ាយរស់ឥតសំខួន.
អ្នកមានព្យាយាមប្រារព្ធមាំមួន បានបេះតាំក្បួនសិល្បសាស្ត្រវិជ្ជា
អ្នកនោះរស់តែមួយថ្ងៃឈ្មោះថា រស់នៅថ្ងៃថ្លាវិសេសលើសលន់.

"ពាក-ធម្មបទ"

អត្តនាយេវ បុរិសោ សេវិតេ មិត្តពន្ធុហិ
អត្តហីនោ នុ បុរិសោ ជីវេបិច មតោបមា!

អ្នកមានទ្រព្យញាតិមិត្រតែងរកប់អាន អ្នកឥតទ្រព្យទោះមានជីវិតនៅ
ក៏លោកប្រៀបទុកដូចជាស្លាប់ទៅ ព្រោះរស់នៅក៏ឥតអំពើដែរ.

" ចាក - កថាកុសុមមញ្ជរី "

សត្តពិន្ទុឱរ- លស្មា សត្តម- តាលបតាលំ
ចន្ទក្កុលេ រវេជាតំ និរជំ ន បស្សតី.

ទោះអ្នកឯណា ទំហំអង្គ ប្រាំពីរដម្រី
កំពស់សេរីល ប្រាំពីរត្នោតក្តី រូបាឥន្ទ្រិយ ធាត់ធំមហិមា
សន្តានអម្បូរ ជាមួយព្រះសូរ្យ នឹងព្រះចន្ទ្រា
ថាបើពុំមាន ធនធានទ្រព្យា អង្គឥតអ្នកណា មួយបទនឹងយល់ឡើយ;
ហេតុយប្រធាន ប្រសើរសោភមាន តែទ្រព្យជាត្រើយ
ជាញាតិជាមិត្រ ស្នេហ៍ស្និទ្ធឯងហើយ ឥតអ្វីទៀតឡើយទ្រព្យជានាថោ.

តិលមត្រិតំ ចកាយមំ ពហុជនោ
បកាសេន្តុំ ហានិទ្ធរតោ មិត្តំរកោ ចសព្វទា.

បើកបទបាលី នេះលោកស្រដី អាថ៌ឧបមា
អ្នកមួយតូចលន់ ខ្លួនប៉ុនល្ងណា ទោះមានទ្រព្យា មានប្រាក់ធនធាន;
មានពាក្យប្រពៃ ចូលចិត្តនរនៃ អ្នកផងសព្វហាន
ឆ្ងាយជិតក្តីណា យាត្រាមកដ្ឋាន រិះរកកប់អាន នៃអ្នកនោះហោង;

សួរសាគរកទៅ សឹងជាញាតិផៅ សន្តានពាក់ទង
សឹងស្គាល់ជាមិត្រ ស្នេហ៍ស្និទ្ធស្នាលស្នង ឥតឯឲ្យហ្មង នៃអ្នកនោះណា.

“ចាក · ច្បាប់សុភាសិត”

យស្ស អត្ថា តស្ស មិត្តា យស្ស អត្ថា តស្ស ពន្ធុ
យស្សត្ថា សោ បុមា លោកេ យស្ស អត្ថា សោ បណ្ឌិតោ.
មានទ្រព្យគង់នឹងមានមិត្រភ្ជា មានទ្រព្យមុខជាមានផៅពង្ស
មានទ្រព្យរាប់ថាប្រុសខ្ពស់ខ្ពង់ មានទ្រព្យជាវង្សបណ្ឌិតជាតិ.

“ចាក · :.ជាកុសុមមញ្ជរី”

មា ចិន្តាបសុតំ តាត! បរតោ ជយំ តណ្ហាហិ?
ចេ’លក្ខោ មា តុណ្ហី ករ! បរសមភារំ តណ្ហា!
កើតមកជាមនុស្សកុំរស់តែលេង ចូរខំប្រឹងប្រែងឲ្យបានឈ្នះគេ
បើមិនបានឈ្នះចូរខំរះរេ! ឲ្យបានស្មើគេក៏ល្អដោយយ៉ាង!

មា ភសធំ បច្ចាសីស! ហុរិមជាតិភាវិតំ!
យា ជាតិ ឃរំវុទ្ធិកា សរដ្ឋំ ធាសំ តកេតិ!
កុំដេកសង្ឃឹមចាំព្រេងសំណាង ដែលខ្លួនកសាងពីជាតិមុនណា
សាសន៍ណាដូច្នោះសាសន៍នោះឈ្មោះថា នាំដែនអាត្មាឲ្យជាខ្ញុំគេ!!!

“ចាក · ភាសិតខ្ញុំ”

ធាត្រសរោ សុរសោឡោ-
ពួកទាហាន សេនាថ្កើងថ្កាន សាហ័សក្លៀវក្លា
បើគ្មានថ្វីដៃ ឥតជ័យចេស្តា ពុំគប់ហៅថា ទាហានឡើយនៃ.

“ពាក-ច្បាប់សុភាសិត”

. . . . . . . . . . . . . . . . . . . . . . . . . . . . .

សង្គាមេ មេ មតំ សេយ្យោ! យញ្ចេ ជីវេ បរាជិតោ!!

. . . . . . . . . . . . . . . . . . . . . . . . . . . . .

ស្លាប់ក្នុងសង្គ្រាមប្រសើរថ្លៃថ្លា! គ្មានខ្មាសអ្នកណា បាត់បង់តែម្តង
រស់នៅចាញ់គេនាំឲ្យមួហ្មង! ខ្មាសទេពតាផងទាំងគង់មនុស្ស!

“ពាក-ធម្មប្រទីបណារ”

បត្តិ មរុក្ខោ ពាណិជ្ជោ មរធារំ
ភិក្ខុ មរសីលំ រាជា មរសង្គាមា
លោកថាសត្វបក្សី សោកទោះបីនឹងមរណា
លុះលើមែករុក្ខា ទើបប្រសើរជាបក្សី;
ឈ្មួញសោកមរណា លើកេត្រាត្រាប់ផលធី
ភិក្ខុទ្រង់សីលវី- សេសសោកមកក្នុងសីលសង្ឃ;
ព្រះមហាក្សត្រធិកជ ទ្រង់អំណាចមរណាក្នុង
សង្គ្រាមជ័យទ្រើសទ្រង់ កេរ្តិ៍ប្រសើរជាក្សត្រា.

“ពាក-ច្បាប់សុភាសិត”

(តមក)

# អំពីវីរបុរស ៤ នាក់

តាំងអំពីកាលនោះមក ប្រជាជនក៏បែកខ្ញែកគ្នាជា ២ ពួក គឺពួកអ្នកមាននិងអ្នកក្រ តាំងតស៊ូគ្នាទៅវិញទៅមកមិនស្ងប់ស្រាក ទាំងពីរពួកសឹងមាននាយកតែរៀងខ្លួន សុទ្ធតែជាមនុស្សសំខាន់ៗ គឺខាងពួកអ្នកមាន មានស៊ីល្ល៉ា និងប៉ុមប៉េ (Sylla et Poumpée) ជាអធិបតី ចំណែកខាងសាមញ្ញជនធម្មតា មានម៉ារីយុស និងហ្ស៊ុលសេសារ (Marius et Jules César) ជាអធិបតី ទាំង ៤ នាក់ បានប្រណាំងប្រជែងគ្នារួមជាគូៗ គឺស៊ីល្ល៉ា និងម៉ារីយុស ប៉ុមប៉េ ហើយនិងសេសារ ។

ម៉ារីយុសជាមេទាហាន ១ ដ៏ល្បីឈ្មោះ ធ្លាប់ធ្វើជាមេទ័ពទៅច្បាំងឈ្នះស៊ីគុរថា (Jugurtha) ដែលធ្លាប់ជាចំណុះរោម បង្កការចលាចលជាក្បត់ឡើង ។ ម៉ារីយុសជាទាហានដ៏អង់អាច ១ មានបំណងចង់បានដំណែងជាកុងស៊ុល ទើបចូលមកក្រុងរោម ប្រើសំដីជាគ្រឿងជួយខ្លួន ទើបបានទទួលនាទីជាកុងស៊ុល មានមុខក្រសួងជាមេទ័ពធំ ដើម្បីធ្វើសង្គ្រាមនឹងស៊ីគុរថាតទៅទៀត ។

កិច្ចការដំបូងដែលម៉ារីយុសបានធ្វើឡើងនោះ គឺការកែប្រែរបៀបកេណ្ឌមនុស្សធ្វើទាហាន គឺបញ្ចូលឲ្យកេណ្ឌអ្នកទីទ័លក្រណាស់នោះចូលធ្វើជាទាហានបានផង ។ វិធីនេះជាវិធីល្អមួយយ៉ាងដែរ ដើម្បីជួយឲ្យក្រុងរ៉ូមមានទាហានថែមច្រើនឡើងទៀត តែនាំឲ្យខូចកេរ្តិ៍ឈ្មោះជាច្រើន គឺពួកនេះស្ម័គ្រចិត្តចូលធ្វើទាហាន ដើម្បីទៅប្លន់យកទ្រព្យសម្បត្តិខាងសឹកសត្រូវ ក្នុងវេលាមានជ័យជំនះ ។ ទាហានអស់នេះមិនសូវគោរពកោតក្រែងខាងច្បាប់ទេ គោតខ្លាចតែមេទ័ពម្នាក់ប៉ុណ្ណោះ ទើបជាឱកាសល្អដល់មេទ័ពបង្គាប់ឲ្យទៅប្លន់ទ្រព្យសម្បត្តិអ្នកស្រុកជារឿយ ៗ ហេតុនេះហើយបានជាមុខក្រសួងបញ្ជាការកងទ័ព ទើបគេត្រូវការប្រាថ្នាចង់បានណាស់ កាលណាមានសង្គ្រាមកើតឡើង ពួកមេទ័ពច្រើនតែដណ្តើមគ្នាធ្វើជាមេទ័ពនាំទ័ពចេញច្បាំង ព្រោះជាផ្លូវហូរចូលមកនៃទ្រព្យសម្បត្តិជាចំនួនច្រើន ។

កាលម៉ារីយុសបានចាត់ការប្រែប្រួលដូចបានពោលមកនេះហើយ ក៏លើកកងទ័ពចេញទៅប្រាបប្រាមស៊ីគុរថា ចាប់ខ្លួនស៊ីគុរថាចូលមកក្រុងរ៉ូម ហើយដាក់គុកទាល់តែស្លាប់ទៅ (មុនគ.ស.១០៤) ។ កាលម៉ារីយុសមានជ័យជំនះគ្រានេះ ក៏បានទទួលដំណែងជាកុងស៊ុលតទៅទៀតជាច្រើនឆ្នាំ ព្រោះបានទទួលដំណែងជាអ្នកប្រាបប្រាមពួកស៊ិមប្រ៍នឹងពួកតឺតុង្ស៍ (Cimbres et Teutons) ដែលចូលមកលុកលុយប្រទេស

ឥតាលី ។ មនុស្ស ២ ពួកនេះ ជាជនជាតិអល្លឺម៉ង់ (ពួកក្រិកនិងពួករ៉ូម៉ាំង ច្រើនហៅថាមនុស្សព្រៃទាំងអស់ ប៉ុន្តែបើពោលតាមពិតនោះមិនមែនជាមនុស្សព្រៃឡើយ ) ដែលលើកទ័ពមកពីមាត់សមុទ្របាល់ទិក (Baltique) ហើយចេញដំណើរដើរកាត់ផែនដីដ៏ធំទូលាយក្នុងទ្វីបឪរុប ព្រមទាំងប្រពន្ធកូន សត្វពាហនៈនិងយានជំនិះ ដើម្បីរកទីកន្លែងតាំងស្រុកទេសឡើង ។ ពួកនេះបានកំចាត់និងទំលាយស្ពានផ្សេងៗតាមផ្លូវដែលខ្លួនលើកទ័ពទៅ ហើយបានសម្លាប់ពួកទាហានរ៉ូម៉ាំងអស់ជាចំនួនច្រើន ។ ក្នុងវេលានោះ ពួកទាហានរ៉ូម៉ាំងដែលចាំស្ទាក់ប្រាំងនឹងមនុស្សព្រៃអស់នោះ មិនមែនជាពួកទាហានដែលមានថ្វីដៃ ថែមទាំងកងកាយនិងកំឡាំងមិនសូវរឹងប៉ឹង ក៏ស៊ូពួកអល្លឺម៉ង់មិនបាន តែចួនជាគ្រាគ្រោះល្អនៃក្រុងរ៉ូម ព្រោះពួកមនុស្សព្រៃនេះមិនបានលើកទ័ពគំហុកហួសចូលទៅក្នុងក្រុងរ៉ូមវេលានោះទេ បែរជាវិលទៅវាយប្លន់ខាងប្រទេសអេស្ប៉ាញវិញ ទើបធ្វើឲ្យម៉ារីយុសមានឱកាសល្មមហ្វឹកហាត់ពួកទាហានរ៉ូម៉ាំងឲ្យបានខ្លាំងពូកែឡើង ។ លុះពួកមនុស្សព្រៃអស់នោះត្រឡប់វិលមកក្រុងរ៉ូមទៀត ទើបត្រូវកងទ័ពម៉ារីយុសប្រាំងទប់ទល់និងសម្លាប់មនុស្សព្រៃអស់នោះបានជាចំនួនច្រើនដល់ ១២០.០០០ នាក់ ។ /

កាលម៉ារីយុសបានធ្វើកិច្ចសំខាន់ៗ សម្រេចបានជាច្រើនលើកដូច្នេះ ទើបធ្វើឲ្យម៉ារីយុសកាន់តែមានអំណាចក្នុងផែនដីរ៉ូមច្រើនឡើងទៀត

បានធ្វើការជួយទំនុកបំរុងជនអ្នកទទួលក្រ ដោយវិធីបែងចែកដីឲ្យយកទៅធ្វើការកសិ៍ ទឹងចំណាយចំណីអាហារឲ្យដោយដំឡៃថោកៗ ។ ក្រៅពីនេះ សេណាត៍ដែលជាសភាខ្ពង់ខ្ពស់បំផុតរបស់ក្រុងរោមតាំងអំពីដើមមកនោះ ក៏ត្រូវម៉ារីយុសបន្ទយអំណាចឲ្យមកនៅក្រោមច្បាប់វិញ ហើយបន្ថែមអំណាចរបស់ប្រជាជនអ្នកស្រុកឲ្យមានច្រើនឡើង បានចេញប្រកាសបញ្ញត្តដល់ទោសប្រហារជីវិតចំពោះឈ្មោះណាមួយដែលព្យាយាមផ្ដាច់ផ្ដិលសិទ្ធិអំណាចរបស់ក្រស្ដប្រជា ។ វិធីនេះក៏ល្អណាស់ដែរ តែម៉ារីយុសអាងដល់បញ្ញត្តិនេះ ហើយកាប់សម្លាប់មនុស្សលេងតាមអំពើចិត្ត ហេតុការណ៍ទាំងនេះធ្វើឲ្យប្រជាជនឆាកប្រែចិត្តគំនិតលែងស្រឡាញ់ម៉ារីយុស ។ ឯពួកជនជាន់អ្នកមានត្រកូលនិងអ្នកមានសម្បត្តិ ជាពួកដែលស្អប់ម៉ារីយុសស្រាប់តាំងពីដើមមកហើយ ថែជាមានអំណាចឡើងវិញដោយមានមនុស្សសំខាន់ម្នាក់ជាប្រមុខឈ្មោះស៊ីល្លា ។

ស៊ីល្លាជានាយទាហានម្នាក់របស់ម៉ារីយុស តាំងអំពីកាលម៉ារីយុសលើកទ័ពទៅប្រាបប្រាមស៊ីគុរថា ជាអ្នកកើតក្នុងត្រកូលខ្ពង់ខ្ពស់ មានសតិបញ្ញាឆ្លៀវឆ្លាត អធ្យាស្រ័យល្អ បានធ្វើការសំខាន់ ១ ជាថ្នាក់ដំបូង គឺប្រាបប្រាមពួកឥតាលីដែលបង្កការចលាចលបានសម្រេច ទើបពួកជនជាន់ខ្ពស់រួមទាំងសភាសេណាត៍ក៏ជឿទុកចិត្ត

(មានត)

# ភូមិសាស្ត្រសង្ខេបនៃនានាប្រទេស

## អំពីភូមិសាស្ត្រសង្ខេបនៃប្រទេសអារ៉ាប់

**ទីតាំងនិងអាណាខេត្ត** នៅទិសខាងជើងនៅក្នុងរយៈរេង អង្សា ១២ ទឹង ៣២ ហើយទិសខាងកើតនៅក្នុងរេងអង្សា ៣៥ ទឹង ៦០ ។ អាណាខេត្តទិសខាងជើងទល់នឹងប្រទេសអ៊ីរ៉ាក់, ស៊ីរីនិងត្រង់ស្សូដានី ទិសខាងលិចទល់នឹងសមុទ្រក្រហម ទិសខាងកើតទល់នឹងឈូងសមុទ្រពែរ៉ុក ទិសខាងត្បូងទល់នឹងសមុទ្រអារ៉ាប់ ។

**ទំហំដី**— ប្រមាណ ២.៥៩០.០០០ គីឡូម៉ែត្រក្រឡា ជាជ្រោយសមុទ្រធំបំផុតមួយ ។

**ផ្ទៃផែនដី**— ផ្ទៃផែនដីនៃជ្រោយសមុទ្រអារ៉ាប់ មានលក្ខណៈជាទីកបខ្ពស់ទូទៅ មានកំពស់តាំងពី ៧៥០ ដល់ ២.១០០ ម៉ែត្រ នៅតំបន់ទិសខាងលិចខ្ពស់ជាងទិសខាងកើត ទីដីទំនាបមានតែតាមជាយមាត់សមុទ្រ ផ្ទៃផែនដីមានតែក្រួសនិងខ្សាច់ទូទៅ វៀរលែងតែក្នុងប្រទេសអ៊ូម៉ង់និងយេមែន សមុទ្រខ្សាច់នៅទិសខាងជើង សមុទ្រខ្សាច់នេហ្វូតនៅកណ្ដាល សមុទ្រខ្សាច់ពេប័ល-ខាលីនៅទិសខាងត្បូង សឹងមិនមានព្រៃព្រឹក្សានិងទន្លេធំៗទេ មានតែជ្រោះជ្រលងដងអូរដែលហូរពីភ្នំចុះទៅក្នុងបឹងត្រពាំង នៅកណ្ដាលសមុទ្រខ្សាច់ ៗ នៅតាមតំបន់បរិវេណដែលមានបឹងឬត្រពាំង

ដងស្ទឹង ច្រើនមានដីដ៏ជាតិល្អ ដំណាំដុះលូតលាស់ល្អ តំបន់ដូច្នេះហៅថា អូអាស៊ិស មានមនុស្សទៅតាំងភូមិលំនៅៗជាច្រើន ។

**ភ្នំ** — ដងភ្នំដែលវែងបំផុតនៅជ្រោយសមុទ្រនេះ គឺភ្នំទីហាម៉ា ដែលលាតសន្ធឹងទៅតាមមាត់ច្រាំងសមុទ្រទិសខាងលិច កំពូលភ្នំដែលខ្ពស់ៗនៅទិសខាងត្បូង កំពូលមានកំពស់ពី ២.៧០០ដល់ ៣០០០ម៉ែត្រ ក៏មាន ដងភ្នំធំ១ផ្នែកទៀតនៅទិសខាងកើតឆៀងខាងត្បូងក្នុងប្រទេសអូម៉ង់ គឺភ្នំឆបេលអគ្គារ កំពស់ពី ២.៧០០ ដល់ ៣០០០ ម៉ែត្រដែរ ។

**ខ្យល់អាកាស** — ក្នុងប្រទេសអូម៉ង់, យេមេននិងដែនអាស៊ីរ មានអាកាសល្អជាងប្រទេសដទៃៗទាំងអស់ គឺមានក្តៅត្រជាក់យ៉ាងកណ្តាល ក្នុងប្រទេសដទៃៗនៅជ្រោយសមុទ្រអារ៉ាប់ច្រើនតែមានអាកាសក្តៅខ្លាំងក្នុងរដូវក្តៅ រងាខ្លាំងក្នុងរដូវរងា ដូចជាប្រទេសនេត់សេត ក្នុងរដូវរងា ត្រឿងកំស់អាកាសចុះទាបដល់ ១២ំ ក្នុងរដូវក្តៅឡើងដល់ ១១២ ក៏មាន ។

ភ្លៀងធ្លាក់នៅប្រទេសអូម៉ង់, យេមេន, និងដែនអាស៊ីរប្រមាណ ៣០៩ មិល្លីម៉ែត្រក្នុង ១ ឆ្នាំ ។ ឯប្រទេសឯទៀតៗមិនសូវមានភ្លៀងឡើយ ។

**ដំណាំ** — ទីដែលដាំដំណាំមានផលល្អមានតិចទេ ការធ្វើស្រែចំការច្បារដំណាំមានតែនៅតាមតំបន់ជាយសមុទ្រនិងអូអាស៊ិស នៅ

កណ្ដាលសមុទ្រខ្សាច់ ។ ដំណាំដែលដាំច្រើន គឺ កាហ្វេ, ល្ង, ស្រូវផ្សេងៗ, ថ្នាំជក់, ឪឡឹក, ល្ពៅ, អំពៅ, គរ, កប្បាស, ដូងជាដើម ។

សត្វ— មានសេះ, លា, ចចក, ទន្សាយ, ឆ្កែព្រៃ, ខ្លា, ឆ្មាព្រៃ, សត្វអូទ្រុស, រមាំង, ក្ដាន់, ពពែ, កែះ, ឧដ្ឋ ។

លោហធាតុ — មានដែក, សំណ, ទង់ដែង, ធ្យូងថ្ម, និងពេជ្រត្បូងផ្សេងៗ ។

ជ្រោយសមុទ្រអារ៉ុបនេះរកស៊ីលក់ដូរនឹងប្រទេសអង់គ្លេស, ឥណ្ឌា, អៀរ៉ង់, និងអ៊ីរ៉ាក់ដោយច្រើន ។ ដំនូញដែលទិញចូលមកមាន ស្រូវ, ម្សៅ, ស្ករ, តែ, គ្រឿងសំលៀកបំពាក់, គ្រឿងដែក, និងរថយន្តជាដើម ។

ប្រជាជន — មានប្រមាណ ១០.០០០.០០០ នាក់ នៅក្នុងប្រទេសនេត់សេត ប្រមាណ៥លាន, ក្នុងប្រទេសយេមេន ៣.៥៧០.០០០, ក្នុងប្រទេសអូម៉ង់, ៥០០.០០០ ក្នុងតំបន់ផ្សេងៗ ក្រៅពីនេះប្រមាណ ១ លាន ។

សាសនា — ពួកអារ៉ុបកាន់សាសនាអ៊ិស្លាមនិកាយស៊ុនី ។

ស្រុកកំពង់ — សេដ្ដា ជាស្រុកកំពង់សំខាន់បំផុតរបស់ប្រទេសនេត់សេត ។

ហូដេដា – ជាស្រុកកំពង់របស់ប្រទេសយេម៉ែន លក់កាហ្វេជាជំនួញចេញជាច្រើន ។

មោកល៉ា – ជាទីក្រុងរបស់ប្រទេស ហ័ជ្រាម៉ាអូត ហើយជាស្រុកកំពង់ធ្វើការលក់ដូរនឹងប្រទេសឥណ្ឌា ។

ស្រុកសំខាន់ៗ — អែរីយ៉ាត-ជាទីក្រុងរបស់ប្រទេសនេត់សេត

មេក្ក – ជាទីក្រុងរបស់ប្រទេសហេត់សាស ពួកជនអិស្លាមតែងនាំគ្នាទៅនមស្ការព្រះនៅស្រុកនេះ ក្នុង១ឆ្នាំៗ ជាច្រើនសែននាក់ ស្រុកនេះជាស្រុកកំណើតរបស់ព្រះមហាម៉ាត់ ។

ម:ឌីន - ជាស្រុកមានជំនួញលក់ដូរច្រើន សពព្រះមហាម៉ាត់កប់នៅស្រុកនេះ ។

ហៃល៍ – ជាទីក្រុងរបស់ដែនឆាំម៉ា

សាប៊ីយ៉ា – ជាទីក្រុងរបស់ដែនអាស៊ីរ

សាណា – ជាទីក្រុងប្រទេសយេមេន

ម័ស្កាត – ជាទីក្រុងប្រទេសអូម៉ង់ ។

របៀបរាជការ — ក្នុងសម័យនេះ អាណាចក្រផ្សេងៗរបស់ពួកអារ៉ាបស្ទើរតែរួបរួមគ្នាតែមួយ ក្រោមអំណាចព្រះមហាក្សត្រប្រទេសនេត់សេត អំណាចអធិបតីទាំងពួងជារបស់ព្រះមហាក្សត្រតែមួយព្រះអង្គៗ

ក្រៅពីនេះ អ្នកគ្រប់គ្រងអាណាចក្រទាំងពួងស្ម័គ្រចូលនៅក្នុងអាណាព្យាបាលរបស់អង់គ្លេសទាំងអស់ មានស្រុកចំណុះអង់គ្លេសសុទ្ធ ។ ពីរស្រុក គឺអាដែននិងកោះប៉េរិម ដែលនៅចំត្រង់ច្រកសមុទ្រក្រហម ។ ស្រុកអាដែន (ជាចំណុះអង់គ្លេសតាំងពី ព.ស.២៣៨២) ជាស្រុកកំពង់សំខាន់បំផុតនៅភាគខាងលិចឆៀងខាងត្បូងនៃទ្វីបអាស៊ី ។

ប្រទេសយេម៉ែន— មានទំហំដីប្រមាណ ១៩៤.២៤០ កិឡូម៉ែត្រក្រឡា ចំនួនមនុស្ស ៣.៥០០.០១០ នាក់ ប្រទេសនេះតាំងនៅលើទីដីកបខ្ពស់ ដែលជាទីល្អបំផុតនៅជ្រោយសមុទ្រអារ៉ុប ទើបមានការដាំដំណាំជាច្រើន គឺ កាហ្វេ, ស្រូវផ្សេងៗ ។ ជំនួញលក់ចេញដែលសំខាន់ គឺកាហ្វេ, ស្បែកសត្វនិងក្លុក ។

ប្រទេសអូម៉ង់ — ទំហំដី ២១២.៣៨០ កិឡូម៉ែត្រក្រឡា ចំនួនមនុស្ស ៥០០.០០០ នាក់, ស្រុកម៉ស្កាតជាទីក្រុង, ស្រុកស្ហួរជាស្រុកកំពង់ធំបំផុត ជំនួញលក់ចេញមានផ្លែល្មុ, ផ្លែទទឹម, គ្រប់ធ្នានិងត្រីងៀត ។

ហ័ដ្រាម៉ូត — ទំហំដី ២២០.៤៤៥ កិឡូម៉ែត្រក្រឡា ចំនួនមនុស្ស ១២០.០០០ នាក់ មានស្រូវនិងស្ករជាជំនួញលក់ចេញ ។

ចប់